លេខ: ០,១០ សកស                                                    សេអ៊ូល, ថ្ងៃទី  ខែ មីនា ឆ្នាំ ២០១០

**សូមគោរពជូន**

**ឯកឧត្តមទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម**

**<u>កម្មវត្ថុ:</u>** សភាពការណ៏សេដ្ឋកិច្ចទូទៅ នៃសាធារណរដ្ឋកូរ៉េ និងទំនាក់ទំនង កម្ពុជា-កូរ៉េ ដើមឆ្នាំ ២០១១

**<u>តាមរយៈ</u> ឯកឧត្តមឯកអគ្គរាជទូត**

ខ្ញុំបាទមានកិត្តិយស សូមគោរពជំរាបជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា សភាពការណ៏សេដ្ឋកិច្ច នៃប្រទេសកូរ៉េ នាបច្ចុប្បន្នកាលនេះ បាននិងកំពុង តែមានសញ្ញាវិជ្ជមាន ដោយសេដ្ឋកិច្ចមានកម្លាំងងើបស្ទុះឡើងវិញ ជាកត្តាធ្វើអោយកូរ៉េ សំរេចបាននូវសម្មិទ្ធិផលធំៗ ជាច្រើននាឆ្នាំ ២០១០ កន្លងមក ។

នៅឆ្នាំ ២០១១ នេះ ដោយសារតែតម្លៃប្រេងឥន្ធនៈ នៅតែមាននិន្នាការកើនឡើងតម្លៃខ្ពស់ជាលំដាប់ ដែលបណ្តាលមកពីកត្តាចំបង នៃភាពមិនទៀងទាត់នៅក្រៅប្រទេស ភាពច្របូកច្របល់នៅមជ្ឈឹមបូពា៌ នៅអាហ្វ្រិកខាងជើង នូវតម្រូវការវត្ថុធាតុដើម និងប្រេងឥន្ធនៈ និងបរិក្ខាផ្សេងទៀតសំរាប់បំរើការផលិត ដើម្បីនាំចេញ បញ្ហាបំណុលរបស់បណ្តា ប្រទេសមួយចំនួននៅតំបន់អឺរ៉ុប វិបត្តិគ្រោះមហន្តរាយនៅជប៉ុន និងបញ្ហាដទៃទៀត ជាដើមហេតុ ធ្វើអោយសន្ទស្សន៏ តម្លៃទំនិញប្រើប្រាស់សព្វសារពើ គ្រឿងឧបភោគបរិភោគ ពោលគឺអតិផរណា មាននិន្នាការកើនឡើង ទៅមុខជាលំដាប់ ។

ចាប់តាំងពីដើមឆ្នាំ ២០១១ មកម្ល៉េះ រដ្ឋាភិបាល ស.កូរ៉េ បានធ្វើការកំណត់គំរោងការណ៏ ដើម្បីជំរុញកំណើនសេដ្ឋកិច្ចរបស់ខ្លួន ទទួលបាន 5% រីឯអតិផរណា នឹងព្យាយាមរក្សាទុកប្រមាណ 3% ។ តែទោះជាយ៉ាងណាក៏ដោយ ស.កូរ៉េ ក៏មិនខុសពីបណ្តាប្រទេសអាស៊ីដទៃទៀត ដែលមានសេដ្ឋកិច្ចលេចធ្លោដទៃទៀតដែរ គឺកំពុងរងនូវផលប៉ះទង្គិច ហើយប្រឈមជាមួយការលំបាក ដោយសារតែអតិផរណាចេះតែកើនឡើងជាលំដាប់ ជាក់ស្តែងអតិផរណានាខែ មករា និងកុម្ភៈ ២០១១ មានក៏រិតលំដាប់ 4.1% និង 4.5% ។

កាលពីឆ្នាំ ២០១០ ការនាំចេញទំនិញ របស់ប្រទេសកូរ៉េ បានឈានទៅដល់ លំដាប់លេខ ៧ ក្នុងចំណោមបណ្តាប្រទេសសំខាន់ៗ នាំចេញបរិមាណច្រើនបំផុត នៅលើពិភពលោក ។ ទូរលេខនាំចេញ នាឆ្នាំ ២០១០ នោះគឺ 467.4 Billion USD ក្នុងខណៈទូរលេខនាំចូល មានចំនួនប្រមាណ 425.7 Billion USD ធ្វើអោយជញ្ជីងពាណិជ្ជកម្មវិជ្ជមាន របស់ប្រទេសកូរ៉េ មានទឹកប្រាក់នៅសល់ (Trade Surplus) រហូតដល់ 41.7 Billion USD ។

តាមការប៉ាន់ស្មាន របស់បណ្តាស្ថាប័នសំខាន់ៗ កូរ៉េ បានអោយដឹងថា កំណើនសេដ្ឋកិច្ច ស.កូរ៉េ នាឆ្នាំ ២០១០ កន្លងមក មានកំរិតប្រមាណជា6.1% ហើយនៅឆ្នាំ ២០១១ នេះ សេដ្ឋកិច្ចមានសន្ទុះកើនឡើងប្រមាណជា5% ។

## ***សភាពការណ៍សេដ្ឋកិច្ច-ពាណិជ្ជកម្ម និងទំនាក់ទំនង កម្ពុជា-កូរ៉េ ដើមឆ្នាំ ២០១១ :***

**I.** *បរិមាណនាំចេញ **ពីកម្ពុជា ទៅកូរ៉េ** ឆ្នាំ ២០០០ ដល់ ឆ្នាំ ២០១០ **គិតជាពាន់ ដុល្លារ អាមេរិក***




*យោងតាម តារាងនិងទូរលេខ ដូចមានជំរាបជូនខាងលើ: នាឆ្នាំ ២០០៩ កន្លងមកនេះ **ទំនិញនាំចេញ ពីកម្ពុជា មកប្រទេសកូរ៉េ** មានទឹកប្រាក់សរុប 18,202,000 US$ កើនឡើងចំនួន 138.7% ប្រៀបធៀបឆ្នាំ ២០១០ ដែលមានទឹកប្រាក់ ចំនួន 43,445,000 US$ ។*

*(កម្ពុជា នាំចេញទៅកូរ៉េ ប្រចាំខែ នាឆ្នាំ ២០១០ ប្រៀបធៀបឆ្នាំ ២០១១)*

*ប្រភពពត៌មាន សមាគមពាណិជ្ជកម្មអន្តរជាតិ នៃប្រទេសកូរ៉េ តម្លៃគិតជា ១០០០ ដុល្លារ*




*កម្ពុជា នាំចេញទៅ កូរ៉េ ប្រចាំខែ នាឆ្នាំ ២០១០*

*កម្ពុជា នាំចេញទៅ កូរ៉េ ប្រចាំខែ នាឆ្នាំ ២០១១*

យោងតាម តារាងនិងទូរលេខ ខាងលើៈ មករា និងកុម្ភៈ ឆ្នាំ ២០១១ នេះ **ទំនិញនាំចេញ ពីប្រទេសកម្ពុជាមកកូរ៉េ** មានទឹកប្រាក់ 5,683,000 US$ និង 4,500,000 US$ កើនឡើងចំនួន 31.2% និង 64.6% ប្រៀបធៀប ខែ ដូចគ្នា ឆ្នាំ ២០១០ ដែលមានទឹកប្រាក់ ចំនួន 4,330,000 US$ និង 1,857,000 US$ ។

**មុខទំនិញសំខាន់ៗ កម្ពុជា នាំចេញទៅ កូរ៉េ តាមលំដាប់ នៃលេខកូដទំនិញ រួមមានៈ ៤០០១២២-៤០០១២៩-៦១០៩១០-៧៦០២០០-៦១០៨២១-៦២០៣៤២-៦៤០៣៩៩-៦១១០២០-៦១០៦១០-៦១០៤៦១-៦១០៥១០ ។**

**II.** បរិមាណនាំចេញ **ពីកូរ៉េ ទៅកម្ពុជា** ឆ្នាំ ២០០០ ដល់ ឆ្នាំ ២០១០ **គិតជាពាន់ ដុល្លារ អាមេរិក**




យោងតាម តារាងនិងទូរលេខ ដូចមានជំរាបជូនខាងលើៈ នាឆ្នាំ ២០១០ កន្លងមកនេះ **ទំនិញនាំចេញ ពីកូរ៉េ មកប្រទេសកម្ពុជា** មានទឹកប្រាក់ 332,998,000 US$ កើនឡើងចំនួន 21.8% ប្រៀបធៀបឆ្នាំ ២០០៩ ដែលមានទឹកប្រាក់ ចំនួន 273,323,000 US$ ។

(កូរ៉េ នាំចេញទៅ កម្ពុជា ប្រចាំខែ នាឆ្នាំ ២០១០ ប្រៀបធៀបឆ្នាំ ២០១១) តម្លៃគិតជា ១000 ដុល្លារ




កូរ៉េ នាំចេញទៅ កម្ពុជា នា ខែ មករា-កុម្ភៈ ឆ្នាំ ២០១០

កូរ៉េ នាំចេញទៅ កម្ពុជា នា ខែ មករា-កុម្ភៈ ឆ្នាំ ២០១១

*យោងតាម តារាងនិងទូរលេខ ខាងលើ: មករា និងកុម្ភៈ ឆ្នាំ ២០១១ នេះ* ***ទំនិញនាំចេញ ពីកូរ៉េ ទៅប្រទេសកម្ពុជា*** *មានទឹកប្រាក់ 5,683,000 US$ និង 4,500,000 US$ កើនឡើងចំនួន 31.2% និង 64.6% ប្រៀបធៀប ខែ ដូចគ្នា ឆ្នាំ ២០១០ ដែលមានទឹកប្រាក់ ចំនួន 4,330,000 US$ និង 1,857,000 US$ ។*

***មុខទំនិញសំខាន់ៗ កូរ៉េ នាំចេញទៅ កម្ពុជា តាមលេខកូដទំនិញ: ៦០០៦២២-៦០០៤១០-៦៣០៩០០-៨៧០៣២៣-៨៧០៤២១-៨៧០២១០-៦០០៦៤២-២៨០២២០-៦២១៧១០-៦២១៦៣២ ។***

**III.** *ពាណិជ្ជកម្ម* ***កូរ៉េ-ពិភពលោក ២០០៤ ដល់ (មករា-វិច្ឆិកា ២០០៩)*** *តម្លៃគិតជា ១០០០ ដុល្លារ*




*យោងតាម តារាងនិងទូរលេខ ខាងលើ: ការធ្វើពាណិជ្ជកម្ម រវាងកូរ៉េ ជាមួយពិភពលោក ឆ្នាំ ២០១០ កន្លងមកនេះ* ***ទំនិញនាំចេញ*** *មានទឹកប្រាក់ 466,383, 762,000 US$ រឺង* ***ទំនិញ នាំចូល*** *មានទឹកប្រាក់ 425,212,160,000 US$ ជញ្ជីងតុល្យភាពពាណិជ្ជកម្មវិជ្ជមាន ដែលមានទឹកប្រាក់នាំចេញ លើសពីទឹកប្រាក់នាំចូល (Trade Surplus) ចំនួន 41,171,601,000 US$ សំរាប់ឆ្នាំ ២០១០ កន្លងមក ។*

*ទូរលេខ ពាណិជ្ជកម្ម* ***កូរ៉េ-ពិភពលោក ឆ្នាំ ២០០៩ និង ឆ្នាំ ២០១០***

| | | **នាំចេញ** | **នាំចូល** | **Trade Balance** |
|---|---|---|---|---|
| 2009 | ឆមាសទី ១ | $ 164.8 billion | $ 145.4 billion | $ 19.4 billion |
| | ឆមាសទី ២ | $ 198.8 billion | $ 177.7 billion | $ 21.1 billion |
| | **Whole year 2009** | **$ 363.5 billion** | **$ 323.1 billion** | **$ 40.4 billion** |
| | ឆមាសទី ១ | $ 221.4 billion (34.3%) | $ 203.9 billion (40.2%) | $ 17.5 billion |

| | | | | |
|---|---|---|---|---|
| 2010 | ឆមាសទី ២ | $ 246.0 billion (23.7%) | $ 221.8 billion (24.8%) | $ 24.2 billion |
| | **Whole year 2010** | **$ 467.4 billion (28.6%)** | **$ 425.7 billion (31.8%)** | **$ 41.7 billion** |

*សូម* ***ឯកឧត្តមទេសរដ្ឋមន្ត្រី*** *មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុត ពីខ្ញុំបាទ ។*

***ទីប្រឹក្សាពាណិជ្ជកម្ម***

***អមស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំទីក្រុងសេអ៊ូល***

***យីវ សុខុម***

***បានឃើញ និង ឯកភាព***

***ដើម្បីជូនជ្រាបជារបាយការណ៍ ដ៏ខ្ពង់ខ្ពស់***

***ឯកអគ្គរាជទូត***

***ចាន់ គីស៊ីម***